# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៣៦៣......សហវ.-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៤

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការតែងតាំងភ្នាក់ងារប្រមូលចំណូលអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសអន្តរក្រសួងមហាផ្ទៃ-សេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ២០៨៧ ប្រក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពីការកំណត់ថ្លៃអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បានឃើញប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- បានឃើញសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់

- បានឃើញសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋទេយ្យចំណូល
- បានឃើញសារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការគ្រប់គ្រងរដ្ឋទេយ្យចំណូល
- បានឃើញប្រកាសលេខ១៤០៥ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការរៀបចំនិងកិច្ចដំណើរការគណនីនៃរដ្ឋទេយ្យចំណូល
- យោងតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុបច្ចុប្បន្ន

## សម្រេច

<u>ប្រការ១</u> : ត្រូវបានតែងតាំង÷

| | | |
|---|---|---|
| ១-លោកឧត្តមសេនីយ៍ត្រី | ឃៀង សុគន្ធា | ប្រធាននាយកដ្ឋានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូល នៅនាយកដ្ឋានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។ |
| ២-លោកវរសេនីយ៍ឯក | មិន សុផេត | នាយការិយាល័យនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។ |
| ៣-លោកវរសេនីយ៍ត្រី | ជា សំអាត | នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តកណ្តាល។ |
| ៤-លោកវរសេនីយ៍ត្រី | ទៀម ធុច | នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង។ |
| ៥-លោកវរសេនីយ៍ទោ | នៅ អេងវណ្ណានី | នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តសៀមរាប។ |
| ៦-លោកវរសេនីយ៍ទោ | ឃឿន សេរីវុឌ្ឍី | នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ។ |
| ៧-លោកវរសេនីយ៍ទោ | ហម រដ្ឋា | នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម។ |
| ៨-លោកវរសេនីយ៍ទោ | អេង ណារ៉ា | នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូល នៅស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង។ |
| ៩-លោកវរសេនីយ៍ទោ | ពិន ស៊ីវុត្ថា | នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូល នៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ។ |
| ១០-លោកវរសេនីយ៍ទោ | ឈុំ ចុន | នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តកោះកុង ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តកោះកុង។ |
| ១១-លោកវរសេនីយ៍ទោ | ថ្មាក់ សុផានិត | នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តកំពត ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តកំពត។ |
| ១២-លោកវរសេនីយ៍ត្រី | សោម ទឿន | នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់។ |
| ១៣-លោកវរសេនីយ៍ទោ | សៅ ស៊ាន | នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ។ |

១៤-លោកវរសេនីយ៍ត្រី ញឹម ទុត្ថា នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តកែប ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តកែប។

១៥-លោកវរសេនីយ៍ត្រី អេច ប៊ុនធឿន នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ។

១៦-លោកវរសេនីយ៍ទោ ហែន ពៅ នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តព្រៃវែង។

១៧-លោកវរសេនីយ៍ត្រី កែទ ភាគ នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង។

១៨-លោកវរសេនីយ៍ទោ អេង សុខលី នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តតាកែវ ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តតាកែវ។

១៩-លោកវរសេនីយ៍ទោ ទូ ប៊ុណ្ណារ៉េត នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តក្រចេះ។

២០-លោកវរសេនីយ៍ត្រី ចាន់ ប៊ុនធឿន នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង។

២១-លោកវរសេនីយ៍ត្រី ឃឹម ថាន្លី នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ។

២២-លោកវរសេនីយ៍ទោ សុត សេរីវឌ្ឍ នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តរតនគិរី ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តរតនគិរី។

២៣-លោកវរសេនីយ៍ទោ ឃុន អ៊ីន នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី។

២៤-លោកវរសេនីយ៍ទោ ព្រាប ធឿន នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន។

២៥-លោកវរសេនីយ៍ត្រី ម៉ូ រស្មី នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ។

២៦-លោកវរសេនីយ៍ត្រី ធឿន លាងហេង នាយការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ ឱ្យទទួលបន្ទុកការងារជាភ្នាក់ងារប្រមូលចំណូលនៅស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ។

<u>ប្រការ២</u> : ភ្នាក់ងារប្រមូលចំណូលអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដូចមានរាយនាមខាងលើ មានភារកិច្ចដូចតទៅ÷

- ត្រូវគ្រប់គ្រងនិងទទួលខុសត្រូវលើចំណូល ដែលប្រមូលបានពីអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ត្រូវបង់ចំណូលពីអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនរជ្ជទេយ្យករចំណូលនៅអមក្រសួងមហាផ្ទៃ
- ត្រូវរៀបចំរបាយការណ៍ស្តីពីស្ថានភាពចំណូលពីអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងរៀបចំរបាយការណ៍ស្តីពីស្ថានភាពបញ្ចូលនិងបញ្ចេញបង្កាន់ដៃបង់ប្រាក់ រួចផ្ញើជូនរជ្ជទេយ្យករចំណូលនៅអមក្រសួងមហាផ្ទៃឱ្យបានទៀងទាត់ប្រចាំខែ។

ប្រការ៣ : សេចក្តីសម្រេចទាំងឡាយដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤ : អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកនៃអគ្គនាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ព្រមទាំងសាមីខ្លួន ដូចមានរាយនាមខាងលើ ត្រូវទទួលបន្ទុកអនុវត្តន៍ប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** |
| **ស ខេង** | **កិត្តិ. អូន ព័ន្ធមុនីរ័ត្ន** |

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៤ "ដើម្បីមុខការ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ